**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

ថ្ងៃសុក្រ ១២កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ១២ ឆ្នាំ២០១៧

# សារលិខិតថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ

## ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មីឆ្នាំសកល២០១៨

**ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!**

ក្នុងឱកាសដ៏នក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល ២០១៨ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមទូលព្រះបង្គំនិងភរិយា សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត ក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរ ថ្វាយ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់កូនចៅប្រជារាស្ត្រ នាំមកនូវសុខសន្តិភាព និងការអភិវឌ្ឍប្រកបដោយភាពសុខដុមរមនា ចម្រុងចម្រើនថ្កុំថ្កើងរុងរឿងទាំងក្នុងពេលបច្ចុប្បន្ននិងទៅអនាគត។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមសម្តែងថ្វាយនូវកតញ្ញូកតវេទិតាដ៏មិយ៉ាងស្មោះស្ម័គ្របំផុត ចំពោះព្រះមហាករុណាទិគុណរបស់ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ដែលព្រះអង្គបានបំពេញព្រះរាជតួនាទីដ៏ឧត្តុង្គឧត្តម ក្នុងព្រះរាជបេសកកម្មដ៏ថ្លៃថ្លារបស់ព្រះអង្គប្រកបដោយទសពិធរាជធម៌ និងជានិច្ចកាលព្រះអង្គតែងបានបំពេញព្រះរាជកិច្ចដោយមិនខ្លាចនឿយហត់ព្រះកាយពល និងព្រះបញ្ញាញាណ ក្នុងបុព្វហេតុបម្រើជាតិមាតុភូមិ។ ព្រមជាមួយនេះព្រះអង្គបានប្រោសព្រះរាជទាននូវព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គយ៉ាងច្រើនសន្ធឹកសន្ធាប់ ជួយដល់ប្រជារាស្ត្រទូទៅ និងតែងយកទឹកព្រះទ័យទុកដាក់ជាទីបំផុតរាល់ព្រះរាជកិច្ចសង្គម នាំមកនូវភាពសុខដុមរមនាជូនប្រជារាស្ត្រទូទាំងប្រទេស។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏មហាជ័យមង្គលនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ ប្រោសព្រះរាជទានប្រសិទ្ធិពរជ័យ មហាប្រសើរ ថ្វាយ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ប្រកបដោយព្រះបរមសុខ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីបានគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ព្រមទាំងប្រជារាស្ត្រខ្មែរអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈទ្រង់ព្រះមេត្តាទទួលនូវគោរវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុត អំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**